

# ព្រះពាយ និងព្រះអាទិត្យ

Kuzhali Manickavel

ដោយសារអ្នកនិពន្ធ វិចិត្រករ និងអ្នកបោះពុម្ពសៀវភៅនេះ
គាំទ្រលើកទឹកចិត្តឲ្យយកស្នាដៃនេះទៅបកប្រែជាភាសាផ្សេងៗ
ពួកគាត់សំណូមពរថារាល់ការកែប្រែផ្នែកសំខាន់
សូមរក្សាយ៉ាងណាកុំឲ្យប្រាសចាកឆ្ងាយពីទម្រង់អត្ថបទ និងរូបភាពដើម។



សម័យថ្ងៃមួយ ព្រះពាយ និងព្រះអាទិត្យ

ហានអួតពីឫទ្ធិអំណាចរៀងៗខ្លួន។



ព្រះពាយ បានពោលដោយអំណួតថា "យើងធ្លាប់រំលើងដើមឈើធំៗ
និងពន្លិចនាវាអស់រាប់លានឯណោះ។
ឯងមិនអាចធ្វើដូច្នេះបានដូចយើងឡើយ។"



ព្រះអាទិត្យ ញញឹម ហើយតបធ្វើហី "គ្រាន់តែប៉ុណ្ណឹងមិនអាចបញ្ជាក់ថា
ឯងខ្លាំងជាងយើងនោះទេ។"



ព្រះពាយ តបវិញថា "យើងអាចឲ្យពពកបាំងឯងឲ្យជិត
ពេលនោះអ្នកណាក៏មើលឯងមិនឃើញដែរ! ប៉ុន្តែឯងវិញ
មិនអាចធ្វើដូច្នេះដាក់យើងបានឡើយ។"



ព្រះអាទិត្យ ញញឹមតិចៗ រួចតបតាមសម្រួលថា "យើងនៅតែគិតថា

យើងខ្លាំងជាងឯង។"



ព្រះពាយ ក៏ចាប់ផ្ដើមសម្ដែងការមិនពេញចិត្ត

ពេលឮថាព្រះអាទិត្យខ្លាំងជាងខ្លួន។ ព្រះពាយក៏លើកយោបល់ថា

"បើដូច្នេះ យើងត្រូវតែសាកល្បងគ្នាទើបបាន។"



រះពាយក្រឡេកមើលជុំវិញដើម្បីរកមធ្យោបាយបង្ហាញអានុភាពរបស់ខ្លួន

ព្រះពាយសួរទៅកាន់ព្រះអាទិត្យថា "ឥឡូវចាំមើលថា

តើអ្នកណាអាចរំលំផ្ទះទាំងនោះឲ្យដួលរាបដល់ដីបានច្រើនជាងគេ?"



ព្រះអាទិត្យក៏តបថា "មិនចាំបាច់ដល់ថ្នាក់នោះទេ

ធ្វើបែបសាមញ្ញទៅបានហើយ។ តើឯងឃើញបុរសនោះទេ?" ព្រះពាយ

ស្ដាប់ហើយក្រឡេកមើលទៅ ឃើញបុរសម្នាក់កំពុងដើរតាមផ្លូវ។

គាត់បង់កក្រមា ដើរហួចម្នាក់ឯងយ៉ាងរីករាយ។



ព្រះពាយពោលថា

"ចាំមើលអ្នកណាអាចធ្វើឲ្យគាត់ប៉ើងចេញពីផ្លូវនេះបានមុនគេ?"

ព្រះអាទិត្យក៏តបវិញថា "ទេ

បែបនេះបានត្រឹមតែធ្វើឲ្យគាត់មានគ្រោះថ្នាក់ប៉ុណ្ណោះ។

ឥឡូវគ្រាន់តែភ្នែនាល់ថា

អ្នកណាអាចធ្វើឲ្យគាត់ដោះក្រមាបង់កចេញទៅបានហើយ។"



ព្រះពាយ យល់ព្រម រួចក៏រសាត់ទៅផ្ដុំលើអាកាស។ បន្ទាប់មកព្រះពាយ
ក៏កួចបោកបក់យ៉ាងវក់វីធ្វើឲ្យប៉ើងជ្រុះស្លឹកឈើពីដើម។
បុរសជ្រួញចិញ្ចើមសម្លឹងមើលទៅលើមេឃ
ហើយប្រឹងក្ដោបកន្សែងបង់ករបស់ខ្លួនយ៉ាងជាប់។



រំពេចនោះពពកខ្មៅលាយឡំនឹងផ្គររន្ទះលេចឡើងពាសពេញមេឃ។

សត្វនានាចាប់ផ្ដើមរត់រកទីជម្រក ឯព្រះពាយ ក៏ចាប់ផ្ដើមគ្រហឹម។

បុរសនោះកាន់តែក្ដោបក្រមាបង់កជាប់ជាងមុន។



មិនយូរប៉ុន្មានផ្គររន្ទះហានស្ងប់ទៅវិញ។ ព្រះពាយ
ប្រឹងផ្លុំឡើងអស់កម្លាំងពីខ្លួន។ ព្រះពាយ

ដង្ហក់ដកដង្ហើមស្ទើរមិនដល់គ្នា។ "ខ្ញុំសុំចុះចាញ់ហើយ។
ខ្ញុំទៅលែងរួចហើយ។" ពោលរួច ព្រះពាយ
ក៏ក្លួចឡើងទៅសម្រាកលើពពក។



ព្រះអាទិត្យ ក៏ពោលឡើងថា "ឥឡូវដល់វេនខ្ញុំហើយ!" ពោលរួច ព្រះអាទិត្យក៏ស្ងាបពត់ខ្លួនបញ្ចេញពន្លឺយ៉ាងរំភើយ។ ព្រះអាទិត្យ បញ្ចេញពន្លឺលើអាកាសកាន់តែខ្លាំងឡើងៗ។ មិនយូរប៉ុន្មាន អាកាសធាតុក៏ប្រែជាក្ដៅហាក់ដូចជានៅរដូវក្ដៅ។



បុរសនោះ សម្លឹងទៅលើមេឃ រួចជូតញើសចេញពីថ្ងាសរបស់គាត់។



គាត់និយាយរអ៊ូតម្នាក់ឯងថា "អាកាសធាតុអីក៏ចម្លែកម៉្លេះថ្ងៃនេះ!"



បន្ទាប់មក គាត់ក៏ដោះក្រមាបង់កយកមកត្របៀតក្លៀក។



"ឯងឈ្នះហើយ!" ព្រះពាយ ព្រមទទួលស្គាល់ដោយរីករាយ។



ព្រះពាយ ទះដ៏ផ្ទែរធ្វើឲ្យស្លឹកឈើរង្គើររិចៗ។



ព្រះអាទិត្យ ញញឹមតបដោយចំអន់លេងថា

"ឯងមិនចាំបាច់ប្រើកម្លាំងហាយបង្ខំឲ្យគាត់ដោះក្រមាបង់កចេញនោះទេ។"



ព្រះពាយ និងព្រះអាទិត្យ សើចជាមួយគ្នា

ហើយតាមមើលបុរសនោះដើរហួចម្នាក់ឯងតាមផ្លូវម្ដងទៀតយ៉ាងរីករាយ។

Brought to you by

The Asia Foundation

Let's Read! is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia. booksforasia.org To read more books like this and get further information, visit letsreadasia.org .

Original Story The Wind and the Sun, author: Kuzhali Manickavel . illustrator: Emanuele Scanziani. Published by BookBox, https://youtu.be/2qaBPthrUqs © BookBox. Released under CC BY-NC-SA 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY-NC-SA 4.0.

CC BY NC SA

For full terms of use and attribution, http://creativecommons.
org/licenses/by-nc-sa/4.0/